# មេរោគថ្មីមួយបង្កជំងឺផ្លូវដង្ហើម ស្រដៀងមេរោគ SRAS ត្រូវបានគេរកឃើញនៅភាគកណ្ដាលប្រទេសចិន

នៅភាគកណ្ដាលប្រទេសចិន កាលពីពេលថ្មីៗនេះ មានមេរោគថ្មីមួយ ដែលបានឆ្លងទៅកាន់មនុស្សចំនួន៥៩នាក់ បង្កឲ្យមានជំងឺផ្លូវដង្ហើម។ យោងតាមអាជ្ញាធរសុខាភិបាលចិន មេរោគថ្មីនេះ ជាប្រភេទស្ថិតក្នុងអំបូរមេរោគ កូរ៉ូណាវីរុស ដូចមេរោគ SRAS។ ដំណឹងនេះ បានធ្វើឲ្យមានការព្រួយបារម្ភ ដោយគេនឹកទៅដល់ ករណីមេរោគ SRAS ដែលបានឆ្លងរាលដាល និងបានសម្លាប់មនុស្ស អស់ប្រមាណ៦០០នាក់ នៅចិន កាលពីឆ្នាំ២០០២ ២០០៣។

នៅទីក្រុងវូហាន ភាគកណ្ដាលប្រទេសចិន នៅចន្លោះពីថ្ងៃទី១២ ដល់ថ្ងៃទី២៩ធ្នូ ឆ្នាំ២០១៩ មានមនុស្សយ៉ាងហោចណាស់៥៩នាក់ ដែលបានធ្លាក់ខ្លួនឈឺ ជួនៗគ្នា។ ៧នាក់ស្ថិតក្នុងអការៈធ្ងន់ធ្ងរ និងអ្នកផ្សេងទៀត ស្ថានភាពជំងឺ ហាក់មានភាពនឹងនរ។ គេសង្ស័យថា ពួកគេបានឆ្លងមេរោគថ្មីម្យ៉ាង។ យោងតាមអាជ្ញាធរសុខាភិបាលចិន អ្នកជំងឺដែលឆ្លងមេរោគនេះ ភាគច្រើន គឺជាអ្នកលក់ដូរ នៅផ្សារលក់ត្រី និងគ្រឿងសមុទ្រ មួយកន្លែង នៅក្នុងទីក្រុងវូហាន។

លោក Xu Jianguo អ្នកស្រាវជ្រាវនៅ បណ្ឌិតសភាវិស្វកម្ម និងវិទ្យាសាស្ត្រចិន បានលើកឡើង នៅក្នុងកាសែតចិនថ្មីថា ក្រុមការងារជំនាញ ទើបតែបានធ្វើការសន្និដ្ឋានជំហានដំបូងថា អ្នកជំងឺទាំងនោះ អាចបានឆ្លងមេរោគថ្មីមួយ ដែលស្ថិតនៅក្នុងអំបូរមេរោគ Coronavirus។ មានករណីផ្ទុកមេរោគនេះ ចំនួន១៥ករណី ដែលត្រូវបានគេរកឃើញហើយ ក្នុងចំណោមអ្នកជំងឺទាំង៥៩នាក់។

អ្នកជំនាញដដែលអះអាងថា មេរោគអំបូរ Coronavirus គឺជាប្រភេទមេរោគ ដែលធ្វើឲ្យអ្នកជំងឺមានអការៈ ក្ដៅខ្លួន ផ្ដាសាយ ឈឺក្បាលជាដើម។ អាការៈជំងឺយ៉ាងសាមញ្ញបែបនេះ គឺជាគ្រោះថ្នាក់ ព្រោះថាអ្នកជំងឺមិនបានចាប់ភ្លឹកដល់ការឆ្លងមេរោគ ខណៈដែលពួកគេអាចប្រឈមនឹងការស្លាប់ នៅពេលមេរោគនេះ បំផ្លាញប្រព័ន្ធផ្លូវដង្ហើម។

តំណាងអង្គការសុខភាពពិភពលោក ប្រចាំក្រុងប៉េកាំង ក៏បានបញ្ជាក់ផងដែរ ថាខ្លួន ទើបតែបានទទួលលទ្ធផលសន្និដ្ឋាន របស់ក្រុមអ្នកជំនាញចិន។ សម្រាប់ពេលនេះ អ្នកជំនាញ នៃអង្គការសុខភាពពិភពលោក កំពុងតែស្រាវជ្រាវបន្ត ដើម្បីស្វែងយល់ពីប្រភព មធ្យោបាយចម្លង និងទំហំគ្រោះថ្នាក់ នៃមេរោគថ្មីនេះ។

គណកម្មការសុខភាពសាធារណៈ ប្រចាំក្រុងវូហាន បានអះអាងថា គេបានដាក់ឲ្យអ្នកផ្ទុកមេរោគនេះ នៅដាច់ដោយឡែក ដើម្បីចៀសវៀងការឆ្លងរាលដាល។ ចំណែកទីតាំង ផ្សារត្រី និងគ្រឿងសមុទ្រ ដែលអ្នកជំងឺភាគច្រើនធ្វើការនៅទីនោះ ត្រូវបានបិទទ្វារជាបណ្ដោះអាសន្ន។ អ្វីដែលជាការព្រួយបារម្ភ គឺពិធីបុណ្យចូលឆ្នាំចិនកាន់តែខិតជិតមកដល់ ដែលការនេះ នឹងធ្វើឲ្យមានចរាចរណ៍មនុស្សចុះឡើងច្រើន ហើយដែលអាចចម្លងមេរោគពីកន្លែងមួយទៅកន្លែងមួយ។ មេរោគថ្មីនេះ បានធ្វើឲ្យគេនឹកឃើញ ទៅដល់ករណីមេរោគ SRAS ដែលស្ថិតក្នុងអំបូរមេរោគ Coronavirus ដែរ។ មេរោគSRAS បានសម្លាប់មនុស្ស ប្រមាណ៦០០នាក់ កាលពីឆ្នាំ ២០០២-២០០៣៕

*ប្រភព ៖ វិទ្យុបារាំងអន្តរជាតិ RFI ចុះផ្សាយនៅថ្ងៃ:09/01/2020 - 17:30*

ឈ្មោះ ៖ ..........................................................................

**សំណួរ ៖**

1. តើអត្ថបទនេះនិយាយអំពីអ្វី?

.......................................................................................................................................

2. អ្នកជំងឺដែលបានឆ្លងមេរោគផ្លូវដង្ហើមនេះ ភាគច្រើនជាអ្នកណា? នៅកន្លែងណា?

.......................................................................................................................................

3. ពួកគេមានអាការៈដូចម្ដេចខ្លះ ពេលដែលបានឆ្លងមេរោគនេះហើយ?

.......................................................................................................................................

.......................................................................................................................................

4. ដើម្បីការពារការរីករាលដាលមេរោគ តើគេមានវិធានការអ្វីខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

5. អំឡុងឆ្នាំ២០០២ ទៅឆ្នាំ២០០៣ តើប្រទេសចិនបានរងគ្រោះដោយជំងឺអ្វីដែរ? ហើយវាមានផលប៉ះពាល់អ្វីខ្លះ?

.......................................................................................................................................

.......................................................................................................................................

**សំណេរ ៖ ចូរអ្នករៀបរាប់ពីវិធីការពារជំងឺរលាកផ្លូវដង្ហើមនេះ។**

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**ការវាយតម្លៃលើកិច្ចការសិស្ស ៖** A: ល្អប្រសើរ B : ល្អណាស់ C : ល្អ D : ល្អបង្គួរ E : មធ្យម F : ខ្សោយ